លោកុ. ៣០:១ ៣១:១២

# ជំពូក ៣០

***ខាទចនា*** *កំណើតកូនប្រុសៗរបស់យ៉ាកុប រ៉ាជែលបង្កើតយ៉ូសែបជូនយ៉ាកុប យ៉ាកុបរៀបចំដំណើរចាកចេញពីផ្ទះឡាបាន់*

នៅក្នុងជំពូកនេះ ព្រះជាម្ចាស់បន្តធ្វើការសម្រេចការងាររបស់ព្រះអង្គ ទោះបីយ៉ាកុបបានប្រព្រឹត្តិអំពើបាបយ៉ាងណាក៏ដោយ។ ព្រះជាម្ចាស់ធ្វើការរបស់ព្រះអង្គមិន មែនដោយសារតែយ៉ាកុបធ្វើបាបនោះទេ ប៉ុន្តែទោះបីយ៉ាកុបធ្វើបាបយ៉ាងណាក៏ដោយ ក៏យ៉ាកុបមិនអាចឃាត់ឃាំងព្រះអង្គ មិនអោយទ្រង់សម្រេចតាមផែនការរបស់ទ្រង់បាននោះទេ។ ប្រធានបទនៃជំពូកនេះ គឺគ្រួសាររបស់យ៉ាកុប ព្រមទាំងកំណើតកូនប្រុសៗ របស់គាត់ទាំងអស់។ យ៉ាកុបមានចិត្តអន្ទះសារចង់ចាកចេញពីផ្ទះឡាបាន់ណាស់ បានជាលោកហ៊ានប្រើល្បិចសម្ងាត់ ដើម្បីធ្វើអោយសម្រេចទិសដៅរបស់ខ្លួន។

## កំណើតកូនប្រុសៗរបស់យ៉ាកុប

**កាលរ៉ាជែលឃើញថា ខ្លួនមិនបានបង្កើតកូនឱ្យយ៉ាកុបសោះ នោះនាងមានចិត្តច្រណែននឹងបងហើយក៏និយាយទៅយ៉ាកុបថា ចូរឱ្យខ្ញុំមានកូនផង បើមិនដូច្នោះខ្ញុំស្លាប់ហើយ (លោកុ.៣០:១)។**

នៅសម័យនោះ ស្ត្រីរូបណាមួយដែលមិនអាចបង្កើតកូនបាន ស្ត្រីរូបនោះ គេរាប់ថាគ្មានមុខ គ្មានមាត់អ្វីនឹងគេទេ ប៉ុន្តែបើមានកូនកាន់តែច្រើន មុខមាត់កាន់តែ ខ្ពង់ខ្ពស់នៅក្នុងគ្រួសារក៏ដូចជានៅក្នុងសង្គមដែរ។

**នោះយ៉ាកុបក៏ខឹងក្តៅចិត្តនឹងរ៉ាជែល ហើយតបថា តើអញជាព្រះឬអីដែលបាន បង្ខាំងមិនឱ្យឯងមាន កូនដូច្នេះ នោះនាងនិយាយថា មើលនុ៎ះន៍ ប៊ីលហាជាបាវស្រីខ្ញុំ សូមឱ្យអ្នកចូលទៅឯវាចុះ ដើម្បីឱ្យវាបានបង្កើតកូនដាក់នៅភ្លៅខ្ញុំ នោះខ្ញុំនឹងបានកូនដោយ សារវា (លោកុ.៣០:២ ៣)។**

ត្រង់នេះយើងឃើញថា លោកយ៉ាកុប ហើយនិងរ៉ាជែលបានយកប្រពៃណីរបស់មនុស្សសម័យនោះ មកអនុវត្តន៍ដូចគេដែរ។ សូមយើងនឹកចាំថា លោកអ័ប្រាហាំ និងសារ៉ាបានធ្វើការដូចគ្នានេះ។ ព្រះជាម្ចាស់មិនយល់ព្រមជាមួយនឹងផែនការដែលអ័ប្រាហាំ និងសារ៉ាធ្វើទេ ហើយឥឡូវនេះ ព្រះអង្គក៏មិនយល់ព្រមចំពោះផែនការ ដែល យ៉ាកុប និងរ៉ាជែលអនុវត្តន៍នេះដែរ។ ព្រះគម្ពីរបានកត់ត្រាទុករឿងរ៉ាវទាំងនេះពិតមែន ប៉ុន្តែមិនមែនមានន័យថា សេចក្តីអ្វីៗទាំងអស់ដែលព្រះគម្ពីរកត់ត្រាទុកមកនោះសុទ្ធតែ មានការយល់ស្របពីព្រះជាម្ចាស់ទាំងស្រុងនោះទេ។ បើនិយាយអោយចំតែម្តង ព្រះជាម្ចាស់មិនយល់ស្របជាមួយនឹងអំពើអាក្រក់ទាំងអស់នោះជាដាច់ខាត។ ហេតុដូច្នេះ ហើយបានជាយើងទាំងអស់គ្នា បានឃើញមានការបែកបាក់គ្នានៅក្នុងគ្រួសាររបស់អ័ប្រាហាំ បន្តមកទៀតមានការបែកបាក់គ្នានៅក្នុងគ្រួសាររបស់អ៊ីសាក។ លុះមកដល់ដំណាក់កាលនេះ គ្រួសារយ៉ាកុបកំពុងតែឈានចូលទៅរកការបែកបាក់ថែមទៀត ហើយយើងឃើញថា ការបែកបាក់ក្នុងគ្រួសារនេះ មានទំហំធំធេងយ៉ាងក្រៃលែង។

នៅក្នុងខជាបន្តបន្ទាប់ខាងក្រោមនេះ យើងឃើញថា យ៉ាកុបបានមានកូន ប្រុសពីរនាក់ទៀត ជាមួយនឹងនាងប៊ីលហា ដែលត្រូវជាឈ្នួលរបស់នាងរ៉ាជែល។ មិន តែប៉ុណ្ណោះ គាត់ក៏បានកូនប្រុសពីរនាក់ទៀតដែរ ជាមួយនឹងនាងស៊ីលផា ដែលត្រូវជាឈ្នួលរបស់នាងលេអា។ ចំណែកនាងលេអាវិញ បានបង្កើតកូនប្រុសពីរនាក់ថែមទៀត ជូនលោកផង។

**ព្រះទ្រង់នឹកចាំពីរ៉ាជែល ក៏ស្តាប់តាមនាង ហើយប្រោសឲ្យនាង បង្កើតកូនបាន នោះនាងមានទំងន់ បង្កើតបានកូនប្រុស១ រូប នាងគិតថា ព្រះទ្រង់បានដកសេចក្តីដំនៀលពីអញចេញ ហើយ នាងឲ្យឈ្មោះថាយ៉ូសែបដោយថា សូមព្រះយេហូវ៉ាបន្ថែមឲ្យខ្ញុំ ម្ចាស់មានកូន១ទៀត (លោកុ.៣០:២២–២៤)។**

កូនប្រុសដែលរៀបរាប់នៅក្នុងខគម្ពីរខាងលើ ជាកូនដែលមានប្រៀបលើកូន នានារបស់លោកយ៉ាកុប។ លោកបានធ្វើដំណើរទៅរស់នៅក្នុងប្រទេសអេស៊ីព្ទនៅពេល លោកពេញកម្លោះ។ យើងនឹងសិក្សាលំអិតពីជីវិតកូនប្រុសម្នាក់នេះ ពីព្រោះគាត់ជាអ្នក ប្តូរវាសនារបស់គ្រួសារយ៉ាកុបទាំងមូល។ ក្រោយមកទៀតនាងរ៉ាជែលបានបង្កើតកូន ប្រុស មួយទៀតជូនយ៉ាកុប ហើយកូនប្រុសនោះឈ្មោះបេនយ៉ាមីន។ នៅចុងបញ្ចប់នៃ ជំពូកនេះ យើងឃើញមានបញ្ជីកូនប្រុសទាំងដប់ពីររូបរបស់យ៉ាកុប ហើយកូនប្រុស ទាំងដប់ពីររូបទាំងនោះ មានសារៈសំខាន់ណាស់ ដ្បិតកុលសម្ព័ន្ធទាំងដប់ពីររបស់ សាសន៍អ៊ីស្រាអែល មានឫសកែវចេញអំពីអ្នកទាំងដប់ពីររូបនេះ។ គ្រាក្រោយមកទៀត ជនជាតិអ៊ីស្រាលែទាំងអស់មានដើមកំណើត ចេញពីកូនរបស់យ៉ាកុបនេះតែ ម្តង។

## យ៉ាកុបរៀបចំធ្វើដំណើរចាកចេញពីផ្ទះឡាបាន់

**កាលរ៉ាជែលសំរាលបានយ៉ូសែបហើយ នោះយ៉ាកុបនិយាយទៅឡាបាន់ថា ខ្ញុំសូមលាលោកឪពុក ត្រឡប់ទៅឯទីកន្លែងខ្ញុំ ឯស្រុកខ្ញុំវិញ ហើយសូមឲ្យប្រពន្ធកូនរបស់ខ្ញុំដែលខ្ញុំ បានបំរើលោកឪពុក ឲ្យបាននេះបានទៅជាមួយនឹងខ្ញុំផង ដ្បិតលោកឪពុកជ្រាបការ ដែលខ្ញុំបានធ្វើជូនរួចហើយ (លោកុ.៣០:២៥–២៦)។**

ឥឡូវនេះ សូមលោកអ្នកស្តាប់សម្តីរបស់ឪពុកធំឡាបាន់ កំពុងដែលគាត់មិនទាន់អស់ មិនទាន់ហើយពីការ ប្រើល្បិចនេះទេ!

**នោះឡាបាន់ឆ្លើយថា បើសិនជាឯងចូលចិត្តនឹងអញ នោះកុំអាល ទៅសិន ពីព្រោះអញយល់ឃើញថា ព្រះយេហូវ៉ាបានប្រទានពរ មកអញដោយព្រោះឯង (លោកុ.៣០:២៧)។**

សម្តីរបស់ឡាបាន់ស្តាប់ទៅហាក់ដូចជាកក់ក្តៅណាស់។ សូមលោកអ្នកនឹកចាំថា សូម្បីស្តេចអ័ប៊ីម៉្មាឡិចជាស្តេចស្រុកកេរ៉ាក៏បានទទួលព្រះពរយ៉ាងខ្លាំងពេលដែល អ៊ីសាកបើផ្ទះសម្បែងទៅរស់នៅក្នុងស្រុកនៃក្សត្រអង្គនេះ។ ឥឡូវនេះ ឪពុកធំយ៉ាកុប នាមឡាបាន់ដឹងថា ព្រះជាម្ចាស់បានគង់ជាមួយនឹងយ៉ាកុប។ គាត់បានទទួលព្រះពរយ៉ាងបរិបូរ ពីព្រះជាម្ចាស់ដោយសារយ៉ាកុបរស់នៅជាមួយនឹងគាត់ ដូច្នេះហើយបានជាគាត់ លួងលោមយ៉ាកុបថា "កូនប្រុសមាសឪពុក កុំប្រញាប់ប្រញាល់ត្រឡប់

ទៅស្រុកវិញធ្វើអ្វី តាំងពីកូនឯងមកនៅជាមួយពុក ទ្រព្យសម្បត្តិពុកដុះដាលវាលគុម្ពខ្លាំងណាស់។ ឪពុកចង់ដំឡើងប្រាក់ខែអោយឯង សុំកុំអោយតែឯងទៅស្រុកចុះ!”

**គាត់ក៏និយាយថា ចូរគិតថ្លៃឈ្នួលឯងចុះ នោះអញនឹងបើកឱ្យ (លោកុ.៣០:២៨)។**

ឥឡូវយ៉ាកុបបានចិត្តក្រអឺតហើយ ពីព្រោះឪពុកក្មេករបស់គាត់ឈ្មោះ ឡាបាន់ នោះ ចង់តថ្លៃមិនចង់អោយលោកចាកចេញពីផ្ទះគាត់ទេ។ ម្តងនេះយ៉ាកុបដឹងច្បាស់ថា គាត់នឹងឈ្នះឪពុកក្មេកគាត់ហើយ។ ដូច្នេះយ៉ាកុបត្រូវតែទទូចសុំដើម្បីចេញពីផ្ទះរបស់ ឪពុកក្មេកគាត់ដើម្បីយកឈ្នះ។

**រួចយ៉ាកុបនិយាយថា លោកឪពុកជ្រាបហើយថា ខ្ញុំបាននៅបំរើលោកឪពុក ហើយថាហ្វូងសត្វលោកឪពុកបានកើតសាយ គ្រាយជាយ៉ាងណា ក្នុងគ្រាដែលខ្ញុំបានឃ្វាល ដ្បិតមុនដែលខ្ញុំមក នោះលោកឪពុកមានតិចណាស់ ឥឡូវនេះវិញ បានចំរើនកើន ឡើងយ៉ាងសន្ធឹក ហើយព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់លោកឪពុកដោយសារខ្ញុំ ឥឡូវនេះ តើចាំដល់កាលណាទៀត ទើបឱ្យខ្ញុំផ្គត់ផ្គង់ដល់គ្រួរបស់ខ្ញុំផង**

**(លោកុ.៣០:២៩–៣០)។**

យ៉ាកុបរអ៊ូរទាំដាក់ឪពុកក្មេកយ៉ាងខ្លាំង។ គាត់និយាយទៅកាន់ឪពុកក្មេកយ៉ាងដូច្នេះថា “ខ្ញុំបម្រើលោកឪពុកយូរឆ្នាំមកហើយ ហើយឈ្នួលដែលខ្ញុំបាននោះ គឺប្រពន្ធពីរ ឈ្នួលរបស់ប្រពន្ធខ្ញុំពីរនាក់ ហើយផ្ទះរបស់ខ្ញុំមានសុទ្ធតែកូនប្រុសៗ”។ មកទល់ពេលនេះ លោកយ៉ាកុបមានកូនប្រុសដប់មួយនាក់ហើយ តើធ្វើដូចម្តេច ដើម្បីអោយគាត់អាច ចិញ្ចឹមកូនទាំងអស់នោះបាន? ដូច្នេះហើយបានជាគាត់និយាយទៅកាន់ឪពុកក្មេកគាត់ថា “ព្រះជាម្ចាស់បានប្រទានពរដល់លោកឪពុក ហើយព្រះអង្គបានធ្វើអោយកេរ្តិ៍អាករ របស់លោកឪពុកដុះដាលវាលគុម្ពច្រើនណាស់ ចំណែកខ្ញុំវិញ មិនទាន់មានអ្វីមួយចំរៀក ទុកចែក កូនទាល់តែសោះ”។

**នោះឡាបាន់សួរថា តើចង់ឱ្យអញឱ្យអ្វីដល់ឯង យ៉ាកុបឆ្លើយថា មិនត្រូវឱ្យអ្វីមកខ្ញុំសោះ បើលោកឪពុកនឹងធ្វើដូច្នេះ នោះខ្ញុំនឹងនៅឃ្វាល ហើយថែរក្សាហ្វូងសត្វរបស់លោកឪពុកទៀត គឺខ្ញុំ នឹងទៅក្នុងគ្រប់ទាំងហ្វូងចៀមរបស់លោកឪពុកនៅថ្ងៃនេះ ដើម្បីនឹងញែកយកអស់ទាំងសត្វពព្លាក់នឹងពពាល ហើយនឹងសត្វខ្មៅ ទាំងអស់ក្នុងកូនចៀមទាំងប៉ុន្មាន ព្រមទាំងសត្វដែលពពាលពព្លាក់ ក្នុងហ្វូងពពែផង**

**ឱ្យបានជាឈ្នួលដល់ខ្ញុំ (លោកុ.៣០:៣១–៣២)។**

ត្រង់នេះ យ៉ាកុបនិយាយថា សត្វដែលមានសម្បុរតែមួយសុទ្ធ ជារបស់ឡាបាន់ ប៉ុន្តែសត្វដែលពពាលពព្លាក់នោះជារបស់លោកវិញ។ យ៉ាកុបនិយាយទៅកាន់ឪពុកក្មេកយ៉ាងដូច្នេះថា “សូមលោកឪពុកអោយសត្វទាំងនោះមកជាឈ្នួលរបស់ខ្ញុំចុះ”។ ឡាបាន់ ស្តាប់ទៅ ហាក់ដូចជាសមរម្យម្យ៉ាងដែរ។

**ដូច្នេះទៅមុខទៀត កាលណាលោកឪពុកចូលមកសាកសួរពីឈ្នួល ខ្ញុំនោះ សេចក្តីសុចរិតរបស់ខ្ញុំ នឹងសំដែងឱ្យឃើញច្បាស់ដូច្នេះ គឺ បើមានសត្វណានៅជាមួយនឹងខ្ញុំ ដែលមិនពពាលពព្លាក់ក្នុងហ្វូង ពពែ ហើយដែលមិនខ្មៅក្នុងហ្វូងចៀម នោះនឹងរាប់ទុកជារបស់លួច ឡាបាន់ក៏និយាយថា អើចូរតាមពាក្យ ឯងចុះ ហើយនៅថ្ងៃនោះឯង ឡាបាន់ក៏ញែកពពែឈ្មោលឆ្នូតៗហើយពពាល នឹងអស់ទាំងពពែញី ដែលពព្លាក់ ហើយពពាលគ្រប់ទាំងសត្វដែល មានសម្បុរ សជុំៗនឹងអស់ទាំងសត្វខ្មៅក្នុងហ្វូង ចៀម ទាំងអស់ ប្រគល់ទៅក្នុងកណ្តាប់ដៃរបស់កូនខ្លួនទាំងប៉ុន្មាន (លោកុ.៣០: ៣៣ ‾ ៣៥)។**

ចាប់ពីពេលនេះទៅសត្វពពាល ហើយនិងសត្វសម្បុរសុទ្ធមិនអាចជាន់គ្នាបានទៀតទេ។ យ៉ាកុបទទួលយកសត្វដែលមានសម្បុរពព្លាក់ សម្បុរឆ្នូតទាំងអស់រួចហើយ យ៉ាកុបអោយពួកសត្វដែលមានសម្បុរតែមួយសុទ្ធជាន់តែគ្នាវាប៉ុណ្ណោះ ដ្បិតសត្វទាំង អស់នោះជារបស់ឪពុកក្មេកគាត់ឈ្មោះឡាបាន់។ សល់ពីនោះសុទ្ធតែជារបស់គាត់ទាំងអស់។ យ៉ាកុបលេងល្បិចមួយក្បាច់នេះ ឆ្លាញ់អស្ចារ្យ។

**រួចគាត់ចេញពីយ៉ាកុបទៅចំងាយដើរផ្លូវអស់៣ថ្ងៃ ឯយ៉ាកុប ក៏ឃ្វាលហ្វូងសត្វរបស់ឡាបាន់ដែលនៅសល់នោះ នោះយ៉ាកុប គាត់យកមែករលួសចំបក់ នឹងក្រចៅស្រស់មកក្រើបកសំបកជាកង់ៗ ឱ្យឃើញសាច់ស ហើយដាក់មែកដែលគាត់បានបកនោះ នៅក្នុងប្រឡាយនឹងស្នូក ជាកន្លែងដែលសត្វមកផឹកទឹក ហើយវា ក៏ជាន់គ្នាក្នុងកាលដែលវាមកផឹកនោះ គឺជាន់គ្នានៅត្រង់មុខ មែកឈើទាំងនោះ នោះក៏បង្កើតកូនមកមានឆ្នូត មានពព្លាក់មាន ពពាល (លោកុ.៣០:៣៦ ‾ ៣៩)។**

មានមនុស្សជាច្រើន ពន្យល់ខុសៗគ្នា អំពីវិធីសាស្រ្តបង្កាត់ពូជសត្វដែលលោក យ៉ាកុបយកមកប្រើនេះ។ អ្នកខ្លះថា មិនគួរជឿទេ ពីព្រោះរឿងនេះ សុទ្ធតែរឿងចៃដន្យ។ រឿងនឹងបើមិនសំខាន់ មិនបាច់មានឯកសារកត់ត្រាទុកនៅក្នុងគម្ពីរឡើយ។ ចំពោះរូបខ្ញុំវិញ ខ្ញុំគិតថា រឿងនេះសំខាន់ហើយ បានជាមានកត់ត្រាទុកនៅក្នុងព្រះបន្ទូលរបស់ព្រះ។ ខ្ញុំជឿថា មានហេតុការណ៍ដែលវាទាក់ទងទៅជាមួយនឹងវិធីសាស្រ្ត បង្កាត់ពូជនេះ ប៉ុន្តែខ្ញុំនៅតែគិតថា ជារឿងចៃដន្យច្រើនជាង។ វិធីសាស្រ្តនេះ ទាំងឡាបាន់ ទាំងយ៉ាកុប ជឿទាំងអស់គ្នាថា របៀបដែលធ្វើនោះ ពិតជាកើតមកដូចចិត្តអ្នក ទាំងពីរចង់បានមែន។ ជំនឿរបស់អ្នកទាំងពីរ ដែលរាប់ថាជាកត្តាសំខាន់ជាទីបំផុតក្នុងរឿងបង្កាត់ពូជសត្វនេះ។ លោកអ្នកប្រហែលជាមិនជឿទេ មើលទៅ ប៉ុន្តែបុរសពីររូបនេះ ជឿឥតសង្ស័យឡើយ។ ប៉ុន្តែ ទោះបីវិធីសាស្រ្តដែលអ្នកទាំងពីរប្រើនោះ មានប្រសិទ្ធិភាព ឬក៏គ្មាន យ៉ាកុបប្រើវិធីសាស្រ្តនោះ ដើម្បីបោកប្រាសឪពុកក្មេកខ្លួន។ គាត់ជាអ្នកបោកប្រាសយ៉ាងចំណាប់ ប៉ុន្តែលុះដល់ពេលដែលមកគាត់ជួបឡាបាន់ ទើបគាត់បានដឹងថា ឪពុកក្មេកគាត់ជាជើងបោកប្រាសយ៉ាងឆ្នើមមួយរូបដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ត្រង់ចំណុចនេះ យើងឃើញថា យ៉ាកុបចាប់ផ្តើមមានប្រៀបជាងឪពុកក្មេកខ្លួនហើយ។ ខ្ញុំអាចនិយាយបានតែត្រឹមហ្នឹងទេអំពីចំណុចខាងលើនេះ ហើយពេលនេះយើងនឹងពិចារណាមើលសេចក្តីបន្តទៅទៀត ដែលនាំអោយយើងឃើញពន្លឺកាន់ តែច្បាស់ឡើង។

ខាងក្រោមនេះ ជាបញ្ជីកូនប្រុសទាំងដប់ពីររូបរបស់យ៉ាកុប។ រយៈពេលយូរ លង់ក្រោយមកទៀត ពូជដែលកើតពីកូនទាំងដប់ពីររូបនោះ បានរីកសាយទៅជាគ្រួសារ ទាំងដប់ពីរអំបូរនៅក្នុងជនជាតិអ៊ីស្រាអែលទាំងមូល។

កូនប្រុសៗទាំងអស់ដែលលេអាបានបង្កើតជូនយ៉ាកុបមាន :

១. រូបេន
២. ស៊ីម្មាន
៣. លេវី
៤. យូដា
៥. អ៊ីសាខា
៦. សាប់យូល៉ូន
៧. ឌីណាជាកូនស្រី

កូនដែលនាងប៊ីលហាជាឈ្នួលរបស់រ៉ាដែលបង្កើតអោយយ៉ាកុបមាន
១. ដាន់
២. ណែបថាលី

កូនដែលនាងស៊ីលផាជាឈ្នួលរបស់លេអាបង្កើតជូនយ៉ាកុបមាន
១. កាឌ
២. អេសើរ

កូនប្រុសដែលរ៉ាដែលបង្កើតជូនយ៉ាកុបមាន
១. យ៉ូសែប
២. បេនយ៉ាមីន

យ៉ាកុបមានកូនប្រុសដប់ពីររូប ដែលសុទ្ធតែឆ្នើមៗជាទីបំផុតក្នុងគ្រប់កិរិយា។ មិនតែប៉ុណ្ណោះ គាត់មានកូនស្រីមួយឈ្មោះនាងឌីណា។

នៅក្នុងជំពូកបន្ទាប់ទៅទៀត យើងឃើញព្រះជាម្ចាស់បានត្រាស់ហៅយ៉ាកុប អោយចាកចេញពីស្រុកខារ៉ាន ដើម្បីត្រឡប់ទៅទឹកដីសន្យា ដែលព្រះអង្គបានប្រទានទៅ អោយលោកអ័ប្រាហាំដល់អ៊ីសាក ព្រមទាំងរូបលោក។ ពេលដែលព្រះជាម្ចាស់ត្រាស់ ហៅអោយលោកត្រឡប់ទៅទឹកដីសន្យាវិញ ព្រះជាម្ចាស់គិតគូរអំពីដំណើរកូនៗរបស់យ៉ាកុបទាំងអម្បាលមាណនោះ។ ព្រះអង្គមិនចង់អោយកូនក្មេងទាំងនោះធំដឹងក្តីនៅក្នុង បរិយាកាសដូចមានរៀបរាប់ក្នុងផ្ទះរបស់ឡាបាន់នោះឡើយ។

# ជំពូក ៣១

*សាវចនា យ៉ាកុបនាំប្រពន្ធកូនរត់ចេញពីស្រុកខារ៉ាន*
*ការតាំងសញ្ញានៅមីសប៉ាស*

នៅក្នុងជំពូក៣១នេះយើងឃើញថា យ៉ាកុបបានចេញពីផ្ទះឡាបាន់ដោយលួចលាក់។ គ្រួសារទាំងពីរមិនបានជប់លៀងធំដុំ លាគ្នាដោយសន្តិវិធីនោះឡើយ។ លុះដល់ពេលឡាបាន់ដឹងពីដំណើរនោះ ឡាបាន់ក៏លើកគ្នាដេញតាមក្រុមរបស់យ៉ាកុប ហើយក៏តាមទាន់ទៀតផង។ នៅទីបញ្ចប់ ឡាបាន់និងយ៉ាកុបបានចុះកិច្ចសន្យាជាមួយគ្នាម្តងទៀត ដើម្បីមិនអោយធ្វើទុក្ខបុកម្នេញដល់គ្នាទៅវិញទៅមក។ លុះភាគីទាំងពីរបានធ្វើ កិច្ចសន្យារួចចប់សព្វគ្រប់ជាមួយគ្នាហើយ គ្រួសារទាំងពីរបានបែកគ្នាក្រោមបរិយាកាស មិត្តភាពជាទីបំផុត។

ព្រះជាម្ចាស់ សព្វព្រះទ័យអោយយ៉ាកុបចាកចេញពីទឹកដីនោះ ដ្បិតព្រះអង្គមិនចង់អោយកូនប្រុសរបស់យ៉ាកុបទាំងដប់ពីរនាក់ ចំឡងអំពើអាក្រក់ដែលគ្រួសារ ឡាបាន់កំពុងតែប្រព្រឹត្តិជារៀងរាល់ថ្ងៃនោះ។ ពួកក្មេងប្រុសៗទាំងនោះ ត្រូវដឹកនាំពូជ អំបូរដប់ពីរនៅក្នុងជនជាតិអីស្រាអែលផង ដូច្នេះហើយបានជាព្រះត្រូវតែអោយកូនទាំងនោះ មកធំដឹងក្តីនៅក្នុងទឹកដីដែលទ្រង់ប្រទានទៅដល់លោកអ័ប្រាហាំវិញ។ អត្ថបទដែលយើងសិក្សានេះ គឺជាព្រះបន្ទូលរបស់ព្រះ ដែលធ្វើអោយមានការល្វែល្វើយ ដល់សេចក្តីត្រូវការរបស់ចិត្តយើងគ្រប់ៗគ្នា។ យើងមានការល្វែល្វើយ ពីព្រោះព្រះ ជាម្ចាស់បានសម្តែងការប្រោសប្រណី ដល់មនុស្សមានបាបមួយរូបដែលបានធ្វើបាប ទាស់ជាមួយព្រះអង្គជាច្រើនអន្លើ ប៉ុន្តែព្រះអង្គមិនបោះបង់ចោលបុគ្គលរូបនេះទេ។ លោកអ្នកបងប្អូនហើយនិងខ្ញុំ គួរទទួលការលើកទឹកចិត្តអំពីហេតុការណ៍ដ៏ល្អនេះ។ ព្រះជាម្ចាស់មិនដែលបោះបង់ចោលយើងរាល់គ្នាឡើយ អោយតែយើងហ៊ានត្រឡប់មករកព្រះអង្គវិញ។ ទ្រង់តែងតែទទួលយើងជានិច្ចជាកាល។ បើប្រសិនណាជាព្រះអាចទទួលមនុស្សប្រភេទយ៉ាកុប ព្រមទាំងមនុស្សប្រភេទដូចរូបខ្ញុំកើត ព្រះអង្គពិតជាអាចទទួល លោកអ្នកបងប្អូនមកវិញកើតជាពិតប្រាកដ។ យ៉ាកុបបានទទួលរងទុក្ខយ៉ាងច្រើនក្នុង ពេលដែលរស់នៅម្ភៃឆ្នាំ ជាមួយឪពុកក្មេកឈ្មោះឡាបាន់នោះ។ ឡាបាន់បានបង្ហាត់ បង្រៀនយ៉ាកុបនៅក្នុងសាលាគម្ពីរ "ទល់ផ្លូក" របស់លោក ហើយចំណែកឯលោកយ៉ាកុបវិញ ត្រូវតែហាត់ពត់លត់ដំខ្លួន បត់បែនតាមស្ថានភាពដែលគាត់ត្រូវតែឆ្លងកាត់ យ៉ាងលំបាកលំបិននោះមក។ ប៉ុន្តែក្រោយពីបានដោះស្រាយរឿងចែកកេ្តីមរតករវាង យ៉ាកុបនិងឡាបាន់ ពិសេសពីរឿងសត្វសម្បុរសុទ្ធ ហើយនិងសត្វសម្បុរពពាលនោះ មកយ៉ាកុបមានទ្រព្យសម្បត្តិច្រើនជាងឡាបាន់ឆ្ងាយណាស់។ ឡាបាន់មិនស្កប់ចិត្តទេ ហើយកូនប្រុសរបស់ឡាបាន់ទាំងអម្បាលមាណ ក៏មិនសប្បាយចិត្តអំពីដំណើរដែល យ៉ាកុបប្រើល្បិចនេះទាល់តែសោះ។

**រួចមកគាត់បានឮពាក្យរបស់ពួកកូនឡាបាន់និយាយគ្នាថា យ៉ាកុប បានលួចរបស់ទ្រព្យឪពុកយើងទាំងអស់ហើយ គឺពីរបស់ឪពុក យើង ទេតើ ដែលវាបានទៅជាមានដូច្នេះ ហើយយ៉ាកុបមើលមុខ ឡាបាន់ឃើញថាមិនសូវស្រួលចំពោះខ្លួនដូចពីដើមទេ (លោកុ. ៣១:១-២)។**

ឥឡូវនេះ ព្រះជាម្ចាស់បានត្រាស់ហៅលោកយ៉ាកុបផ្ទាល់ខ្លួនតែម្តង!

**ព្រះយេហូវ៉ាទ្រង់មានបន្ទូលនឹងយ៉ាកុបថា ចូរឯងវិលត្រឡប់ទៅ ក្នុងស្រុកឪពុកឯង ឯញាតិសន្តានឯងវិញទៅ នោះអញនឹងនៅជាមួយនឹងឯង យ៉ាកុបគាត់ចាត់គេឱ្យទៅហៅរ៉ាជែលនឹងលេអា មកឯងហ្វូងសត្វត្រង់ទីវាល (លោកុ.៣១:៣-៤)។**

ព្រះជាម្ចាស់ត្រាស់ហៅអោយយ៉ាកុបចាកចេញពីទឹកដីនោះ ដូច្នេះព្រះអង្គក៏រៀបចំផ្លូវ ដើម្បីអោយយ៉ាកុបមានលទ្ធភាពអាចធ្វើការនោះកើត។ យ៉ាកុបបានបបួលប្រពន្ធទាំងពីរនាក់ គឺរ៉ាជែលនិងលេអា ដើម្បីទៅជំនុំគ្នានៅឯចំការពីព្រោះគាត់ខ្លាច ឈ្នួលបម្រើ ឬឡាបាន់ដឹងពីផែនការសម្ងាត់របស់លោក។ យ៉ាកុបពិតជាមិនចង់ អោយនរណាដឹងពីផែនការសម្ងាត់ដែលគាត់បានធ្វើជាមួយនឹងរ៉ាជែលនឹងនាងលេអា នោះឡើយ។

**ប្រាប់ថា អញឃើញឫកពាររបស់ឪពុកឯង ហាក់ដូចជាមិនសូវ ស្រួលនឹងអញដូចពីដើមសោះ តែព្រះនៃឪពុកអញទ្រង់បានគង់ នៅជាមួយនឹងអញឯងក៏ដឹងថា អញបានបំរើឪពុកឯងអស់ពី កំឡាំងដែរ តែឪពុកឯងបានបញ្ឆោតអញ ហើយបានបំផ្លាស់ឈ្នួល របស់អញ១០ដងហើយ (លោកុ.៣១:៥-៦)។**

បើនិយាយតាមពិតត្រង់ទៅ ក្នុងខនេះយើងឃើញថា យ៉ាកុបជាមនុស្សល្អម្យ៉ាងដែរ ពីព្រោះគាត់ធ្វើការយ៉ាងក្តៅគគុកគ្រប់ពេលវេលា ដើម្បីបានអោយប្រាក់ ឈ្នួលដែលគាត់ទទួលនោះ។ ប៉ុន្តែឡាបាន់ជាមនុស្សល្អម្យ៉ាងដែរ ពីព្រោះដោយសារគាត់បានបង្ហាត់បង្រៀនអោយយ៉ាកុបចេះធ្វើការធ្ងន់ធ្ងរបែបនេះ។ ឡាបាន់ចាយលុយ ហើយមិនអោយឥតកំរៃទេ ហើយគាត់ធ្វើបែបនេះ ចំពោះកូនប្រសាធ្លាតរបស់គាត់ ឈ្មោះយ៉ាកុប។

**តែព្រះទ្រង់មិនព្រមបើកឱកាសឱ្យគាត់ប្រទូស្តចំពោះអញទេ (លោកុ.៣១:៧)។**

សូមមើលចុះ លោកតាឡាបាន់ប្រើអកប្បកិរិយា ក្រឡិចក្រឡុច ដូរដោះឈ្នួល ដែលលោកបំរុងអោយយ៉ាកុបនេះចំនួនដប់ដង ក្នុងពេលម្ភៃឆ្នាំ។ អ្ហ៎! គួរអោយអាណិតដល់យ៉ាកុបដ៏កំសត់នេះណាស់។ ទាល់តែប្រឈមមុខនឹងស្ថានការណ៍ដែលទាល់ច្រក រកនរណាពឹងពាក់មិនបាន ទើបគាត់ក៏បែរមករកព្រះ ហើយព្រះជាម្ចាស់ក៏ចូលមក ធ្វើអន្តរាគមន៍ក្នុងរឿងក្តីរបស់លោក។

**កាលណាគាត់ថា សត្វពពាលនឹងបានជាឈ្នួលឯង នោះពួកសត្វ មេៗទាំងអស់កើតកូនមកសុទ្ធតែពពាល បើកាលណាគាត់ថា សត្វឆ្នូតនឹងបានជាឈ្នួល ឯងនោះពួកមេៗទាំងអស់ក៏កើតកូនមក សុទ្ធតែឆ្នូតដែរ**

**ដូច្នេះព្រះទ្រង់បានដកហ្វូងសត្វរបស់ឪពុកឯង ប្រទានមកឱ្យអញវិញហើយ (លោកុ.៣១:៨‑៩)។**

យ៉ាកុបពន្យល់ដល់រ៉ាជែលនិងលេអាថា ព្រះជាម្ចាស់បានប្រទានពរដល់គាត់បានជាឡាបាន់ ហើយនិងពួក កូនប្រុសរបស់គាត់ច្រណែនជាមួយនឹងលោក។ អ្នកទាំងអស់នោះ មិនគ្រាន់តែច្រណែនតែប៉ុណ្ណោះទេ គេនាំគ្នាព្រួតស្អប់យ៉ាកុបថែមទៀតផង។

ពេលនេះយ៉ាកុបបានពណ៌នាអំពីមូលហេតុពិតប្រាកដ ដែលគាត់ចង់ចាកចេញពី ស្រុក របស់ឪពុកក្មេកខ្លួន។

**នោះទេវតានៃព្រះយេហូវ៉ា មានបន្ទូលមកអញក្នុងសប្តិនោះថា យ៉ាកុបអើយ អញទូលឆ្លើយថា ព្រះករុណាវិសេសព្រះអម្ចាស់ នោះទ្រង់មានបន្ទូលថា ចូរឯងងើបភ្នែកឡើង មើលទៅសត្វ ឈ្មោល ទាំងប៉ុន្មាន ដែលជាន់ញីនោះ មានឆ្នូត មានពពាល ហើយប្រផេះ ដ្បិតអញបានឃើញអស់ទាំងការ**

**ដែលឡាបាន់ បានធ្វើដល់ឯង (លោកុ.៣១:១១‑១២)។**

លោកអ្នកបងប្អូនខ្លះប្រហែលជាមិនទាន់ស្កប់ចិត្តទេ ដ្បិតនៅក្នុងជំពូកកន្លងទៅ ខ្ញុំមិនបានពន្យល់អោយបាន ល្អិតល្អន់ពីដំណើរបង្កាត់ពូជសត្វនោះ។ ខ្ញុំរង់ចាំមកដល់បទគម្ពីរត្រង់នេះ ទើបខ្ញុំពន្យល់អំពីមូលហេតុដែលសត្វទាំងនោះកើតមកយ៉ាងដូច្នោះ។ ពូជនោះ បានសាយគ្រាយកូន ដោយសារតែមូលហេតុម្យ៉ាងគត់ គឺដោយសារព្រះជាម្ចាស់ មានបន្ទូលយ៉ាងដូច្នេះថា "គឺអញបានធ្វើការនោះ!" ត្រង់ចំណុចនេះ យើងមិនចាំបាច់ស្វែងរកការពន្យល់ណា ពីផ្នែកធម្មជាតិដែលបង្កើតអោយមានសត្វប្រភេទនោះមកយ៉ាង ដូច្នេះទេ។ ខ្ញុំទុកចិត្តថា ព្រះជាម្ចាស់ប្រើវិធីនោះ ដើម្បីអោយមានពូជសត្វ ឆ្នូត ពពាល ប្រផេះ សម្រាប់យ៉ាកុបទទួលជាមរតក។ មានការពន្យល់ច្រើនបែបច្រើនយ៉ាង ហើយលោកអ្នកបងប្អូនអាចជ្រើសរើសយកណាមួយ

ក៏បាន។ ប៉ុន្តែចំណែកខ្ញុំវិញ ខ្ញុំជ្រើសរើស យកការពន្យល់មួយនេះ ពីព្រោះព្រះជាម្ចាស់មានបន្ទូលយ៉ាងដូច្នេះថា "ដ្បិតអញបាន ឃើញអស់ទាំងការដែលឡាបាន់បានធ្វើដល់ឯង ដូច្នេះហើយ បានជាអញប្រទានពរដល់ ឯង"។ កាលណាអ្វីដែលព្រះជាម្ចាស់សម្រេចនឹងធ្វើក៏បានសម្រេចចេញបែបនោះជាប្រ ត្យក្ស។